អង្គការ REDRESS

បញ្ចប់អំពើទារុណកម្ម ស្វែងរកយុត្តិធម៌សម្រាប់អ្នកនៅរស់រានមានជីវិត

# គំនិតសម្រាប់លទ្ធភាពនៃការផ្តួចផ្តើម ទាក់ទងនឹងជនរងគ្រោះដែល អ.វ.ត.ក អាចអនុវត្ត តាមលក្ខខណ្ឌនៃមាត្រា ២ នៃសេចក្តីព្រៀងកិច្ចព្រមព្រៀងបន្ថែម

## ១. ប្រវត្តិ

អង្គការ REDRESS ចាប់ដៃគូជាមួយក្តីករុណា ដើម្បីរៀបចំការសិក្សាពហុប្រទេស អំពីឱកាសក្នុងការសងសំណង ទៅអ្នកនៅរស់ពីអំពីហឹង្សាផ្លូវភេទទាក់ទងនឹងជម្លោះ របស់មូលនិធិអ្នកនៅរស់ពិភពលោក នៅក្នុងប្រទេសកម្ពុជា។ ការសិក្សាផ្តោតលើស្ថានភាពនៃការទូទាត់សំណង និងឱកាសក្នុងការសងសំណង សម្រាប់អ្នកនៅរស់ពីអំពីហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ នៅតាមបណ្តាប្រទេសជាងម្ភៃ។ ការសិក្សាមានគោលបំណងផ្តល់អនុសាសន៍ សម្រាប់សកម្មភាពបន្តទៀត ផ្អែកលើតម្រូវការនិងការជម្រុញរបស់អ្នកនៅរស់។ ក្នុងរយៈពេលប្រាំខែចុងក្រោយ REDRESS បានធ្វើការស្រាវជ្រាវផ្អែកលើឯកសារមានស្រាប់ (Desk-based research) យ៉ាងលម្អិត រួមមានការត្រួតពិនិត្យជាប្រព័ន្ធ ទៅលើការផ្សព្វផ្សាយដែលពាក់ព័ន្ធ ព័ត៌មានជាមូលដ្ឋានអំពីជម្លោះ ការត្រួតពិនិត្យជាប្រព័ន្ធ ទៅលើព័ត៌មានដែលមានស្រាប់ អំពីវិសាលភាព ទំហំ និងលក្ខណៈនៃអ្នកនៅរស់ពីអំពីហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ ព្រមទាំងទិន្នន័យពីអ្នកនៅរស់ ដែលក្តីករុណាបានធ្វើការសម្ភាសន៍ នៅក្នុងប្រទេសកម្ពុជា។ REDRESS ក៏បានធ្វើការសម្ភាសន៍អ្នកពាក់ព័ន្ធ ជាមួយអតីតមេធាវី និងមេធាវីបច្ចុប្បន្នរបស់ដើមបណ្តឹងរដ្ឋប្បវេណី សមាជិកសង្គមស៊ីវិល អ្នកជំនាញនិងអ្នកសិក្សាស្រាវជ្រាវ នៅក្នុងនិងក្រៅប្រទេសកម្ពុជា។ ការសិក្សានិងការចូលរួមរបស់អ្នកនៅរស់ គឺកំពុងតែដំណើរការ ប៉ុន្តែក្តីករុណានិង REDRESS បានឈានដល់ការសន្និដ្ឋានបឋម ហើយបានបោះពុម្ពផ្សាយ របាយការណ៍សង្ខេបរបស់ប្រទេសកម្ពុជា ជាមួយមូលនិធិអ្នកនៅរស់ពិភពលោក។ សំណើសុំនេះរួមមានកម្មវិធីទូទាត់សំណង ដែលត្រូវបាន

ពិចារណា ដោយមានការផ្តោតជាពិសេសទៅលើអ្នកនៅរស់ពីអំពីហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ ហើយក៏អាចអនុវត្តផងដែរចំពោះអ្នកនៅរស់ពីរបបនេះ ក្នុងលក្ខណៈទូលាយផងដែរ។

## ២. លទ្ធផលបឋម នៃការស្រាវជ្រាវអំពី អ.វ.ត.ក និងសំណង

. អ្នកនៅរស់ជាច្រើនមានការអន់ចិត្ត ដោយតុលាការកម្រិតកំណត់សំណងរបស់ខ្លួនត្រឹមតែសំណងសមូហភាព និងផ្លូវចិត្ត ព្រោះពួកគាត់នៅបន្តរស់នៅក្នុងភាពក្រីក្រ។

. គម្រោងសំណងដែល អ.វ.ត.ក ទទួលស្គាល់ គឺមិនមានការទទួលស្គាល់ណាមួយពីការទទួលខុសត្រូវរបស់រដ្ឋ ហើយគម្រោងទាំងនោះមិនមានការគាំទ្រពីរដ្ឋនិងនយោបាយឡើយ ព្រោះគម្រោងទាំងនោះផ្តល់មូលនិធិទាំងស្រុង ដោយអ្នកផ្តល់ជំនួយ។

. គម្រោងជាច្រើនបានដំណើរការរួចទៅហើយ ហើយសឹងតែជិតបញ្ចប់ទៅទៀត នៅពេលដែល អ.វ.ត.ក ទទួលស្គាល់ពួកគេថាជាគម្រោងសំណង។

. អ្នកទទួលផល ជាញឹកញាប់មិនបានសូម្បីតែដឹងថា ពួកគាត់បានចូលរួមក្នុងគម្រោងសំណង។ លើសពីនេះទៀត ការផ្តោតរបស់ អ.វ.ត.ក ទៅលើក្រុមធំនៃដើមបណ្តឹងរដ្ឋប្បវេណី មានន័យថាការបំពេញតាមតម្រូវការជាក់លាក់ របស់អ្នកនៅរស់ពីអំពីហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ គឺមិនមែនជាអាទិភាពឡើយ នៅពេលសម្រេចផ្តល់សំណង។

. ដោយសារតែគម្រោងសំណង គឺទទួលមូលនិធិទាំងអស់ដោយអ្នកផ្តល់ជំនួយ និរន្តរភាពនៃគម្រោងគឺមិនអាចធានាបានឡើយ ហើយគម្រោងភាគច្រើនបានឈានដល់ការបញ្ចប់ សូម្បីតែអ្នកនៅរស់ជាច្រើន ជាពិសេសអ្នកនៅតាមតំបន់ជនបទ មិនបានទទួល ឬទទួលបានមិនគ្រប់គ្រាន់ នូវសេវាដែលគម្រោងទាំងនោះបានផ្តល់ជូន។

. ដោយសារតែ អ.វ.ត.ក ដាក់បញ្ចូលតែការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងសំណុំរឿង ០០២/២ ដោយមិនបញ្ចូលទម្រង់ដទៃទៀត នៃអំពើហឹង្សាផ្អែកលើយេនឌ័រ ឬផ្លូវភេទ អ្នកនៅរស់ពីអំពីហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ ជាច្រើន មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយមិនអាចតស៊ូមតិ សម្រាប់សំណងដែលពួកគេត្រូវការ ឬមានសិទ្ធិទទួលគម្រោងសំណង។

. អ្នកនៅរស់ជាច្រើនជាមនុស្សចាស់ រស់នៅក្នុងភាពក្រីក្រ ហើយត្រូវបានដកចេញពីសង្គម ដោយរស់នៅតាមតំបន់ជនបទ ហើយមិនចេះអក្សរ។ ពួកគាត់ភាគច្រើនបានស្លាប់។ ហេតុដូច្នេះ ពេលវេលាគឺមានសារៈសំខាន់ណាស់ ប្រសិនបើត្រូវធ្វើការវាយតម្លៃបន្ថែម ឬសិក្សាបន្ថែមទៀត នៅមុនពេលអនុវត្តវិធីសាស្ត្រសំណង។

. មានតែគម្រោងសំណងមួយគត់របស់ អ.វ.ត.ក ដែលផ្តោតពិសេសលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមិនបានឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវ ថាតើការរៀបការដោយបង្ខំមានភាពឃោឃៅបែបណា នៅទូទាំងប្រទេសកម្ពុជា នៅក្នុងរបបនោះ ឬថាតើមនុស្សច្រើនប៉ុណ្ណាដែលទទួលរងផលប៉ះពាល់ ពីការរៀបការដោយបង្ខំនេះ។

. អ.វ.ត.ក គ្រាន់តែដោះស្រាយទៅលើទម្រង់មួយ នៃអំពើហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ គឺការរៀបការដោយបង្ខំ ដោយលម្អិតនៅក្នុងសាលសវនាការ (ដោយមានករណីលើកលែងតែមួយគត់ គឺការរំលោភផ្លូវភេទ ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស នៅក្នុងសំណុំរឿង ០០១)។ ហេតុដូច្នេះ អ្នកនៅរស់មួយក្រុម ដែលអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានឆ្លុះបញ្ចាំងដោយត្រឹមត្រូវ ទៅលើរាល់ប្រភេទនៃអំពើហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម។ កម្មវិធីសំណង និងការផ្តល់ប្រឹក្សាបន្ថែមទៀត ចាំបាច់ត្រូវផ្តល់មិនត្រឹមតែអ្នកដែលត្រូវបានទទួលស្គាល់ ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលទម្រង់ដទៃទៀត នៃអំពើហឹង្សាផ្អែកលើយេនឌ័រ ឬផ្លូវភេទ។

### ៣. ការអនុវត្តដែលស្នើឡើង

### ក. <u>ការគាំទ្រសម្រាប់កម្មវិធីសំណងរដ្ឋបាលនៅទូទាំងប្រទេស</u>

យន្តការនៅសេសសល់របស់ អ.វ.ត.ក អាចផ្តល់ជំនាញបច្ចេកទេស ដល់រដ្ឋាភិបាលកម្ពុជា ក្នុងការជួយដល់ការដាក់ដំណើរការកម្មវិធីសំណងរដ្ឋបាល ដែលអ្នកនៅរស់អាចទទួលបាន ដោយមិនចាំបាច់មាន អ.វ.ត.ក។

<u>ហេតុផល</u>

អំពើហឹង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ និងឧក្រិដ្ឋកម្មដទៃទៀត ដែលបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម មានមូលហេតុជាច្រើន ដែលបណ្តាលឲ្យមានការបាត់បង់ជាក់ស្តែង ក្នុងចំណោមអ្នកដែលនៅរស់ ដែលជីវភាព

របស់ពួកគេត្រូវខូចខាត ដោយសារបទពិសោធន៍របស់ពួកគេ។ ឧទាហរណ៍មួយក្នុងចំណោមនោះគឺ ការបាត់បង់ទ្រព្យសម្បត្តិ និងការរំខានដល់ការងារឬការអប់រំ។ ជាលទ្ធផល អ្នកនៅរស់ជាច្រើនបន្តទទួលរងភាពក្រីក្រ ដែលធ្វើឲ្យកាន់តែធ្ងន់ធ្ងរ ដល់ការលំបាកដែលពួកគេជួបប្រទះ ក្នុងការទទួលបានសេវាសុខាភិបាល ផ្លូវច្បាប់ និងសេវាគាំទ្រដទៃទៀត។ ការប៉ះទង្គិចផ្លូវចិត្ត និងការខូចខាតចំពោះគុណភាពជីវិត សេដ្ឋកិច្ចសង្គម ដែលអ្នកនៅរស់ទទួលរង ក៏មានផលប៉ះពាល់យូរអង្វែង ទៅលើក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ ផលប៉ះពាល់ទាំងនោះបន្តជាច្រើនជំនាន់ ហើយរួមមាននូវភាពក្រីក្រ កម្រិតការអប់រំទាប និងភាពគ្មានការងារធ្វើ។ កម្មវិធីសំណងរដ្ឋបាល ដែលតាមរយៈនោះអ្នកនៅរស់ពីរបបខ្មែរក្រហម អាចទទួលបានការទូទាត់សរុបជាបុគ្គល ឬប្រភេទនៃប្រាក់សោធននិវត្តន៍ ដែលអនុញ្ញាតឲ្យពួកគាត់ អាចឆ្លើយតបតាមតម្រូវការជាច្រើន ដែលជាប់ពាក់ព័ន្ធនឹងភាពជាជនរងគ្រោះរបស់ពួកគាត់។ នេះក៏ជាមធ្យោបាយមួយផងដែរ ក្នុងការទទួលស្គាល់ស្ថាប័នរបស់ជនរងគ្រោះ ទៅលើការរស់នៅផ្ទាល់ខ្លួនរបស់ពួកគេ ដោយសារតែកម្មវិធីនេះធ្វើឲ្យពួកគេ អាចចាយវាយលុយទៅតាមអ្វីដែលពួកគេយល់ថាសមស្រប។

<u>ក្រុមគោលដៅ</u>

ជនរងគ្រោះនៃរបបខ្មែរក្រហម ដោយផ្តល់អាទិភាពជាពិសេសទៅលើអ្នកដែលរស់នៅក្រោមបន្ទាត់ក្រីក្រ។ សិទ្ធិទទួលបានសំណងរដ្ឋបាល មិនគួរភ្ជាប់ជាមួយការទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង អ.វ.ត.ក ឡើយ។

<u>ពេលវេលាសមស្រប</u>

យន្តការនៅសេសសល់របស់ អ.វ.ត.ក អាចជួយដល់រដ្ឋាភិបាល ក្នុងការបង្កើតគម្រោង និងកំណត់អំពីមធ្យោបាយ ក្នុងការផ្តល់ហិរញ្ញវត្ថុដល់គម្រោងនោះ ដោយគិតពិចារណាដល់ការធានាថា រដ្ឋាភិបាលកម្ពុជា អាចដំណើរការកម្មវិធីដោយឯករាជ្យ បន្ទាប់ពីរយៈពេលបីឆ្នាំដំបូង។

**ខ. <u>ការគាំទ្រចំពោះកម្មវិធីផ្តល់អត្តសញ្ញាណប័ណ្ណ នៅទូទាំងប្រទេស ដែលជាប់ទាក់ទងជាមួយកម្មវិធីសំណង</u>**

យន្តការនៅសេសសល់របស់ អ.វ.ត.ក អាចផ្ដល់ជំនាញបច្ចេកទេស ដល់រដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតកម្មវិធីមួយ ក្នុងការផ្ដល់អត្តសញ្ញាណប័ណ្ណ សម្រាប់អ្នកនៅរស់ពីរបបខ្មែរក្រហម ដើម្បីឲ្យពួកគាត់អាចទទួលបានការថែទាំចិត្តសាស្ត្រនិងវេជ្ជសាស្ត្រគ្រប់គ្រាន់ និងមិនគិតថ្លៃ និងទម្រង់នៃសំណងដទៃទៀត។

<u>ហេតុផល</u>

សូមមើលហេតុផលនៅផ្នែក ក. ខាងលើ។ អ្នកនៅរស់នៅតែទទួលរងជំងឺផ្លូវចិត្តនិងផ្លូវកាយរយៈពេលវែង ហើយជាញឹកញាប់ពួកគាត់ មិនអាចទទួលបានការថែទាំគ្រប់គ្រាន់ ឬសមស្របឡើយ។

<u>ក្រុមគោលដៅ</u>

ជនរងគ្រោះនៃរបបខ្មែរក្រហម ដោយផ្ដល់អាទិភាពជាពិសេសទៅលើអ្នកនៅរស់ ពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ។ សិទ្ធិទទួលបានសំណងរដ្ឋបាល មិនគួរភ្ជាប់ជាមួយការទទួលស្គាល់ថាជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង អ.វ.ត.ក ឡើយ។

<u>ពេលវេលាសមស្រប</u>

យន្តការនៅសេសសល់របស់ អ.វ.ត.ក អាចជួយដល់រដ្ឋាភិបាល ក្នុងការបង្កើតកម្មវិធី និងកំណត់អំពីមធ្យោបាយ ក្នុងការផ្ដល់ហិរញ្ញវត្ថុដល់កម្មវិធីនោះ ដោយគិតពិចារណាដល់ការធានាថា រដ្ឋាភិបាលកម្ពុជា អាចដំណើរការកម្មវិធីដោយឯករាជ្យ បន្ទាប់ពីរយៈពេលបីឆ្នាំដំបូង។

**គ. <u>ការគាំទ្រដល់អង្គការចិត្តសង្គមអន្តរវប្បធម៌ និងការបណ្ដុះបណ្ដាលអ្នកចិត្តសាស្ត្រនៅទូទាំងប្រទេស</u>**

យន្តការនៅសេសសល់របស់ អ.វ.ត.ក អាចផ្ដល់ការគាំទ្រហិរញ្ញវត្ថុចំពោះ អង្គការចិត្តសង្គមអន្តរវប្បធម៌ ដើម្បីផ្ដល់សេវាដល់អ្នកនៅរស់ នៅតាមសហគមន៍ឆ្ងាយៗ ដើម្បីបន្តការងាររបស់ពួកគេ ក្នុងការផ្ដល់ការព្យាបាលច្រើនជំនាន់ ដល់ក្រុមគ្រួសារ និងផ្ដល់ការគាំទ្រផ្នែកចិត្តសាស្ត្របន្ថែមទៀត ដល់អ្នកនៅរស់ពីអំពើហិង្សាផ្លូវភេទ ទាក់ទងនឹងជម្លោះ។ ពួកគេអាចផ្ដល់ហិរញ្ញវត្ថុផងដែរ ដល់ការបណ្ដុះបណ្ដាលអ្នកចិត្តសាស្ត្របន្ថែមនៅទូទាំងប្រទេស ដើម្បីធានាថាមានអ្នកនៅរស់ អាចទទួលសេវាថែរក្សាផ្លូវចិត្តកាន់តែទូលំទូលាយ។

<u>ហេតុផល</u>

សូមមើលហេតុផលនៅផ្នែកខាងលើ។ អ្នកនៅរស់នៅតែទទួលរងបញ្ហាផ្លូវចិត្តរយៈពេលវែង ហើយជាញឹកញាប់ពួកគាត់ មិនអាចទទួលបានការថែទាំគ្រប់គ្រាន់ឡើយ ជាពិសេសនៅពេលដែលពួកគាត់ រស់នៅតាមតំបន់ដាច់ស្រយាល។ ការព្យាបាលបែបសក្ខីកម្មរបស់ អង្គការចិត្តសង្គមអន្តរវប្បធម៌ គឺជាទម្រង់ពិសេសមួយនៃការព្យាបាលផ្អែកលើសិទ្ធិមនុស្ស ដែលធ្វើឲ្យអ្នកនៅរស់ ចូលរួមក្នុងការអធិប្បាយ និងកត់ត្រាបទពិសោធន៍នៃការប៉ះទង្គិចរបស់ពួកគេ ហើយក្នុងពេលជាមួយគ្នា ផ្តល់ឱកាសក្នុងការបង្កើតឡើងវិញ នូវការចងចាំអំពីការប៉ះទង្គិចទាំងនោះ ហើយស្វែងរកការគាំទ្រពីក្រុមគ្រួសារ និងសហគមន៍របស់ពួកគាត់។

<u>ក្រុមគោលដៅ</u>

ជនរងគ្រោះនៃរបបខ្មែរក្រហម ដោយផ្តល់អាទិភាពជាពិសេសទៅលើអ្នកនៅរស់ ពីអំពើហិង្សាផ្លូវភេទទាក់ទងនឹងជម្លោះ ដោយមិនកម្រិតត្រឹមអ្នកដែលទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង អ.វ.ត.ក ឡើយ។

<u>ពេលវេលាសមស្រប</u>

ជាការប្រសើរ យន្តការនៅសេសសល់របស់ អ.វ.ត.ក គួរគាំទ្រដល់អង្គការចិត្តសង្គមអន្តរវប្បធម៌ ក្នុងអាណត្តិបីឆ្នាំរបស់ខ្លួន។

**ឃ. <u>ការរៀបចំពិធីអាពាហ៍ពិពាហ៍ សម្រាប់អ្នកនៅរស់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលចង់បានការរៀបចំបែបនេះ</u>**

យន្តការនៅសេសសល់របស់ អ.វ.ត.ក គួរគាំទ្រដល់ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលរៀបចំពិធីអាពាហ៍ពិពាហ៍ សម្រាប់គូស្រករដែលត្រូវបានបង្ខំ ឲ្យរៀបការនៅក្នុងរបបខ្មែរក្រហម ហើយដែលសម្រេចចិត្តរស់នៅជាមួយគ្នានាពេលក្រោយមក។ ការរៀបចំនេះនឹងកាត់បន្ថយភាពអាម៉ាស់មួយចំនួន ដែលជនរងគ្រោះមាន ដោយសារតែពួកគេមិនមានពិធីរៀបអាពាហ៍ពិពាហ៍បែបប្រពៃណី។ នេះគឺជាមធ្យោបាយបែបច្នៃប្រឌិត និងមិនទូទៅ ដែលឆ្លើយតបចំពោះតម្រូវការមួយចំនួន ដែលអ្នកនៅរស់បានលើកឡើង។

<u>ហេតុផល</u>

គូរស្រករជាច្រើនដែលត្រូវបានបង្ខំឲ្យរៀបការ បានសម្រេចចិត្តរស់នៅជាមួយគ្នា បន្ទាប់ពីបញ្ចប់របបខ្មែរក្រហម ប៉ុន្តែពួកគាត់ទទួលរងភាពអាម៉ាស់ ដោយសារតែមិនមានពិធីរៀបអាពាហ៍ពិពាហ៍បែបប្រពៃណី។ អ្នកត្រូវបានសម្ភាសន៍ជាច្រើន សម្រាប់ការសិក្សានេះបានលើកឡើងថា គូរស្រករដែលត្រូវបានបង្ខំឲ្យរៀបការ នៅក្នុងរបបខ្មែរក្រហម ហើយកូនរបស់ពួកគាត់មិនត្រូវបានទទួលស្គាល់ ដោយសហគមន៍របស់ពួកគេទេ ព្រោះការរៀបការរបស់ពួកគាត់ មិនធ្វើតាមប្រពៃណីខ្មែរ។

ក្រុមគោលដៅ

គូស្រករដែលត្រូវបានបង្ខំឲ្យរៀបការ ហើយដែលចង់បានពិធីរៀបអាពាហ៍ពិពាហ៍បែបប្រពៃណី។ ពួកគាត់អាចកំណត់បានដោយមានការជួយពីអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ ពិធីរៀបអាពាហ៍ពិពាហ៍ប្រហែល ៥០០ ពិធី នឹងអាចត្រូវធ្វើឡើងនៅទូទាំងប្រទេស

ពេលវេលាសមស្រប

ជាការប្រសើរ យន្តការនៅសេសសល់របស់ អ.វ.ត.ក គួរគាំទ្រដល់ពិធីបែបនេះ ក្នុងអាណត្តិបីឆ្នាំរបស់ខ្លួន។

**ច. កម្មវិធីពិភាក្សាច្រើនជំនាន់**

យន្តការនៅសេសសល់គួរគាំទ្រដល់កម្មវិធីពិភាក្សាច្រើនជំនាន់ (កម្មវិធីខ្លះគឺជាផ្នែកនៃគម្រោងសំណង ដែលដំណើរការដោយក្តីករុណា អង្គការចិត្តសង្គមអន្តរវប្បធម៌ និងអង្គការដទៃទៀត) ដើម្បីឈានឆ្ពោះទៅដល់ការធានាថា ជំនាន់ក្រោយ ជាពិសេសកូនៗនៃអ្នកដែលត្រូវបានបង្ខំឲ្យរៀបការ យល់ដឹងអំពីភាពអាម៉ាស់ និងការប៉ះទង្គិចដែលឪពុកម្តាយរបស់ពួកគេបានទទួលរង។

ហេតុផល

ការរៀបការដោយបង្ខំបង្ករឲ្យមានការលំបាកនិងការប៉ះទង្គិចផ្នែកអារម្មណ៍យ៉ាងខ្លាំង ដល់ក្រុមគ្រួសារ ដោយបង្កើតជាបរិយាកាសមួយ ដែលអាចនាំដល់ការរំលោភបំពាន ដូចជាអំពើហឹង្សាក្នុងគ្រួសារ។ អ្នកផ្តល់សម្ភាសន៍បានពន្យល់ថា បើទោះបីជាក្នុងប្រទេសកម្ពុជា អាចលែងលះគ្នាបានក្តី តែគូរស្រករដែលត្រូវបានបង្ខំឲ្យរៀបការ ហើយមានកូន ជាញឹកញាប់នៅរស់នៅជាមួយគ្នា ក្រោយរបបខ្មែរក្រហម។ ប៉ុន្តែគូរស្រករទាំងនោះ ពេល

ខ្លះមិនមានទំនាក់ទំនងអារម្មណ៍ ហើយក្រុមគ្រួសារអាចទទួលរងដោយអារម្មណ៍ខឹង និងអន់ចិត្ត។ លើសពីនេះ កូនៗដែលកើតចេញពីការរៀបការដោយបង្ខំ ជាញឹកញាប់មិនបានដឹងថា ឪពុកម្តាយរបស់ពួកគេ ត្រូវបានបង្ខំឲ្យរៀបការឡើយ ដែលធ្វើឲ្យកាន់តែអាក្រក់ដល់អារម្មណ៍ នៃការច្របូកច្របល់។ អង្គការមិនមែនរដ្ឋាភិបាលបានរកឃើញថា គំនិតផ្តួចផ្តើមការពិភាក្សាច្រើនជំនាន់ មានផលប៉ះពាល់វិជ្ជមានខ្លាំង ទៅលើក្រុមគ្រួសារដែលទទួលរងពីបញ្ហានេះ។ ប៉ុន្តែពួកគេមិនអាចទៅដល់ប្រជាជនភាគច្រើនឡើយ ដោយសារអស់ថវិកា បន្ទាប់ពីគម្រោងសំណងបានបញ្ចប់ ហើយអ្នកនៅរស់ជាច្រើន រស់នៅតំបន់ជនបទដែលពិបាកទៅដល់។

<u>ក្រុមគោលដៅ</u>

អ្នកនៅរស់ពីការរៀបការដោយបង្ខំ និងក្រុមគ្រួសាររបស់ពួកគេ ជាពិសេសអ្នកដែលមានកូនកើតចេញពីការរៀបការដោយបង្ខំ។ គំនិតផ្តួចផ្តើមនេះមិនគួរកម្រិតត្រឹមតែជនរងគ្រោះ ដែលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៃសំណុំរឿងរបស់ អ.វ.ត.ក ឡើយ។

<u>ពេលវេលាសមស្រប</u>

ជាការប្រសើរ យន្តការនៅសេសសល់របស់ អ.វ.ត.ក គួរគាំទ្រដល់កម្មវិធីបែបនេះ ក្នុងអាណត្តិបីឆ្នាំរបស់ខ្លួន។

**<u>ច. គំនិតផ្តួចផ្តើមការចងចាំ</u>**

ទោះបីជាសំណុំរឿង ០០២/១ មានគម្រោងសំណង ដែលពាក់ព័ន្ធការបោះផ្សាយកូនសៀវភៅ អំពីអង្គហេតុដែលត្រូវបានជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ក្តី តែការបោះផ្សាយបែបនេះ មិនបានបន្តរមកសំណុំរឿង ០០២/០២ ដែលជាសំណុំរឿងតែមួយគត់ ដែលលើកឡើងជាច្រើន នូវអំពីហឹង្សាផ្លូវភេទយ៉ាងទូលំទូលាយ នៅក្នុងទម្រង់នៃការរៀបការដោយបង្ខំឡើយ។ ការបោះផ្សាយកូនសៀវភៅបែបនេះ អាចជួយបំពេញចន្លោះប្រហោងនោះ។ បន្ថែមលើនេះ យន្តការនៅសេសសល់របស់ អ.វ.ត.ក គួរពិចារណាគំនិតផ្តួចផ្តើមគាំទ្របន្ថែមដូចជាមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ទាក់ទងទៅនឹង អ.វ.ត.ក ការបង្កើតនូវមធ្យោបាយសំណងក្រោយមានសាលដីកាសំណុំរឿង០០២/០២ ដើម្បីធានាថាសាធារណជន អាចប្រឹក្សាជាមួយឯកសារតុលាការជាសាធារណៈ រួមទាំងភស្តុតាង នៅពេលរាប់សិបឆ្នាំទៅមុខទៀត ហើយឧក្រិដ្ឋកម្មពាក់ព័ន្ធអំពីហឹង្សាផ្លូវភេទទាក់ទងនឹងជម្លោះត្រូវបញ្ចូលហើយដាក់បង្ហាញ ក្នុងលក្ខណៈបែបរសើប នៅក្នុងគំនិតផ្តួចផ្តើមបែបនោះផងដែរ។ ក៏គួរ

តែលើកឡើងផងដែរអំពីការប្រឹងប្រែងសម្រាប់ការចងចាំ ដោយតួអង្គសង្គមស៊ីវិល ដូចជាមជ្ឈមណ្ឌលបុប្ផាណា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអាចរួមបញ្ចូលផងដែរ នៅក្នុងយុទ្ធសាស្ត្រនៃការចងចាំ នៃយន្តការនៅសេសសល់។

<u>ហេតុផល</u>

សំណុំរឿង ០០១ និង ០០២ សុទ្ធតែមានគម្រោងសំណង ដែលមានគោលដៅលើការចងចាំ និងថែរក្សាចំណេះដឹងអំពីរបបខ្មែរក្រហម។ ប៉ុន្តែមិនមានគម្រោងណាមួយ ផ្ដល់ជាពិសេសទៅលើអំពីហិង្សាផ្លូវភេទឡើយ។ ហេតុដូច្នេះ កូនសៀវភៅអំពីអង្គហេតុ ដែលត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ គឺសំខាន់ណាស់សម្រាប់ការរក្សាកំណត់ត្រា និងកេរ្តិ៍ដំណែលរបស់តុលាការ។ នៅក្នុងគម្រោងសំណងរបស់ខ្លួន អ.វ.ត.ក ជាញឹកញាប់ផ្ដោតសំខាន់លើសារសំខាន់ នៃការចងចាំអតីតកាល និងបង្រៀនជំនាន់ក្រោយអំពីអតីតកាលនោះ។ អង្គហេតុដែលបានជំនុំជម្រះ ក្នុងសំណុំរឿង០០២/០២ រួមទាំងការរៀបការដោយបង្ខំ គឺជាផ្នែកមួយដ៏សំខាន់នៃប្រវត្តិសាស្ត្ររបស់កម្ពុជា។

<u>ក្រុមគោលដៅ</u>

សាធារណជនកម្ពុជា

<u>ពេលវេលាសមស្រប</u>

ជាការប្រសើរ យន្តការនៅសេសសល់របស់ អ.វ.ត.ក គួរគាំទ្រដល់គំនិតផ្ដួចផ្ដើមបែបនេះ ក្នុងអាណត្តិបីឆ្នាំរបស់ខ្លួន។

ពី៖ Lisa-Marie Rudi Lisa-Marie@redress.org

ផ្ញើរ៖ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០២១ ម៉ោង ២០:៥៤

ជូន៖ កែវ សុទ្ធី Keo.Sothie@eccc.gov.kh ស៊ីម សូរិយា sorya.sim@un.org

ចម្លងជូន៖ Alejandra Vicente Alejandra@redress.org Julie Bardeche juli@redress.org Director director@kdei-karuna.org

កម្មវត្ថុ៖ Re: សារណារបស់ REDRESS អំពីគំនិតសម្រាប់មុខងារនៅសេសសល់របស់ អ.វ.ត.ក

ជូនចំពោះលោក សុទ្ធី

ខ្ញុំសង្ឃឹមថាលោកបានទទួលសារអេឡិចត្រូនិកនេះហើយ។ ខ្ញុំបានដឹងថាលោកបានបញ្ជូនរបាយការណ៍របស់លោកហើយ។ សូមអបអរសាទរ។ ពួកយើងរង់ចាំអនុវត្តតាមដំណើរការ ដូចដែលលោកនឹងធ្វើការប្រឹក្សានៅក្នុងខែឧសភា។

នាពេលថ្មីៗនេះ យើងខ្ញុំបានដាក់បង្ហាញនូវលទ្ធផលរបាយការណ៍បឋម ជូនទៅក្រុមអ្នកនៅរស់ ៦០នាក់ ហើយពួកគាត់ភាគច្រើនលើកឡើងថា ពួកគាត់ចង់ឲ្យមានការប្រជុំទ្រង់ទ្រាយធំចុងក្រោយមួយ រវាងអ្នកនៅរស់និងបុគ្គលិក អ.វ.ត.ក នៅមុនពេលបិទបញ្ចប់ អ.វ.ត.ក។ ខ្ញុំចង់លើកឡើងពីចំណុចនេះប្រាប់ទៅលោក ដោយសារតែអ្នកនៅរស់បានស្នើសុំពួកយើង ឲ្យជម្រាបដល់លោក ហើយដោយសារតែនេះគឺជាអ្វីដែលពួកយើង បានដាក់បញ្ចូលផងដែរ នៅក្នុងសារណារបស់យើង ផ្ញើរជូនលោក ប្រសិនបើយើងខ្ញុំបានដឹងអំពីបញ្ហានេះ នៅពេលនោះ។

ក្តីករុណានឹងធ្វើការរៀបចំការប្រឹក្សាជាមួយអ្នកពាក់ព័ន្ធ នៅក្នុងខែមករា នៅរាជធានីភ្នំពេញ ដែលក្នុងពេលប្រឹក្សានោះ ពួកគេនឹងចែករំលែកអំពីលទ្ធផលបឋមរបស់ពួកយើង ហើយយើងនឹងបោះពុម្ពផ្សាយរបាយការណ៍នេះ នៅក្នុងអំឡុងរដូវផ្ការីកឆ្នាំ២០២២ ហើយច្បាស់ណាស់ថាពួកយើងនឹងចែករំលែករបាយការណ៍នេះជាមួយលោក។

កិច្ចសន្យារបស់ខ្ញុំជាមួយ REDRESS នឹងបញ្ចប់នៅដំណាច់ឆ្នាំនេះហើយ ប៉ុន្តែអ្នករាល់គ្នាដែលនៅក្នុងផ្នែកចម្លងជូននៃសារអេឡិចត្រូនិកនេះ នឹងបន្តអនុវត្តគម្រោងនេះ។

ជូនពរឲ្យលោកទទួលបានសេចក្តីសុខ សុភមង្គលនៅដំណាច់ឆ្នាំនេះ

ដោយក្តីគោរព

Lisa